**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ក្រុមប្រឹក្សាជាតិគណនេយ្យ**
លេខ....០០១...... ក.ជ.គ........

# សារាចរណែនាំ
# ស្ដីពី
# បែបបទ នីតិវិធី និងលក្ខខណ្ឌក្នុងការទទួលបានសិទ្ធិបន្តចុះហត្ថលេខា លើរបាយការណ៍គណនេយ្យ ឬ/និង របាយការណ៍សវនកម្ម សម្រាប់គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស

អនុលោមតាមប្រកាសលេខ ១០៣ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្ដីពីការអនុញ្ញាតឱ្យគណនេយ្យករជំនាញ និងសវនករប្រតិស្រុត ជាជនបរទេស មានសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍ សវនកម្ម ក្នុងគោលបំណងពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍការប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា, ក្រុមប្រឹក្សាជាតិគណនេយ្យ សូមធ្វើការណែនាំដូចខាងក្រោម÷

## ក- លក្ខខណ្ឌនៃការស្នើសុំចុះបញ្ជី

គណនេយ្យករជំនាញ ឬ/និងសវនករប្រតិស្រុត ជាជនបរទេស ដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំមកប្រធាន **ក.ជ.គ.** តាមរយៈអគ្គលេខាធិការដ្ឋាននៃ **ក.ជ.គ.** និងត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

### ក១. លក្ខខណ្ឌសម្រាប់ការស្នើសុំការចុះបញ្ជីលើកដំបូង (សិទ្ធិចុះហត្ថលេខា)

- បានរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងតិចរយៈពេល៦០ថ្ងៃ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជី និង ត្រូវរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី ១៨២ ថ្ងៃ ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទទួលបានសិទ្ធិ
- មានសមាជិកភាពជាគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញ (ASEAN MRA on Accountancy) សម្រាប់បុគ្គលដាក់ពាក្យដែលមានសញ្ជាតិអាស៊ាន (ASEAN Nationality)
- បានចុះបញ្ជីជាគណនេយ្យករជំនាញបរទេស (RFPA) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញ (ASEAN MRA on Accountancy)
- ជាបុគ្គលដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប (Fit & Proper)
- មានបណ្ណ ឬសៀវភៅការងារដែលចេញដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ឬមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី-ខេត្ត។

### ក២. លក្ខខណ្ឌសម្រាប់ការស្នើសុំបន្តចុះបញ្ជីរូបវន្តបុគ្គល (សិទ្ធិចុះហត្ថលេខា)

- បានរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី ៩០ថ្ងៃ ក្នុងឆ្នាំ២០១៩ និងត្រូវរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី ១៨២ ថ្ងៃ ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទទួលបានសិទ្ធិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
Website: www.naccambodia.gov.kh
Email : info@naccambodia.gov.kh
ទូរស័ព្ទ: ៨៥៥-២៣ ៤៣២ ១៥៤/៨៥៥-២៣ ៤៣២ ១៧៤
Phone: 023 432 154 / 023 432 174

- មានសមាជិកភាពជាគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញ (ASEAN MRA on Accountancy) សម្រាប់បុគ្គលដាក់ពាក្យដែលមានសញ្ជាតិអាស៊ាន (ASEAN Nationality)
- បានចុះបញ្ជីជាគណនេយ្យករជំនាញបរទេស (RFPA) ស្របតាមកិច្ចព្រមព្រៀងទទួលស្គាល់អញ្ញមញ្ញ (ASEAN MRA on Accountancy)
- ជាបុគ្គលដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប (Fit & Proper)
- មានបណ្ណ ឬសៀវភៅការងារដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត។

**ខ- លក្ខខណ្ឌនៃការផ្តល់សិទ្ធិចុះហត្ថលេខា**

ការអនុញ្ញាតផ្តល់ជូនសិទ្ធិចុះហត្ថលេខា ដល់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ជាជនបរទេស អគ្គលេខាធិការដ្ឋាននៃ **ក.ជ.គ.** នឹងធ្វើការពិនិត្យលម្អិតលើលក្ខខណ្ឌ ដូចខាងក្រោម÷

- បានបំពេញរាល់លក្ខខណ្ឌក្នុងចំណុច ក១ ឬ ក២
- បានចូលរួមសកម្មភាពជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ តាមការស្នើសុំក្នុងគោលបំណងអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា (ករណីការស្នើសុំបន្ត)
- បានបំពេញការបណ្តុះបណ្តាលជាប្រចាំដើម្បីរក្សាបាននូវសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសេវាយ៉ាងតិចចំនួន ៤០ ម៉ោង ក្នុងមួយឆ្នាំ
- ពុំធ្លាប់ទទួលរងការប្តឹងពីសាធារណៈជន ឬពីអតិថិជនរបស់ខ្លួន មកអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

**គ- ឯកសារភ្ជាប់**

**គ១. រូបវន្តបុគ្គល**

១. លិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច (ផុតសុពលភាពមិនលើសពី៦ ខែ)

២. លិខិត ឬវិញ្ញាបនបត្រសមាជិករបស់ **វ.គ.ស.ក.**

៣. វិញ្ញាបនបត្រគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) សម្រាប់បុគ្គលស្នើសុំមានសញ្ជាតិអាស៊ាន (ASEAN Nationality)

៤. វិញ្ញាបនបត្រចុះបញ្ជីគណនេយ្យករជំនាញបរទេស (RFPA) សម្រាប់បុគ្គលស្នើសុំមានសញ្ជាតិអាស៊ាន (ASEAN Nationality)

៥. លិខិតឆ្លងដែនមានសុពលភាពយ៉ាងតិច៦ខែ និងឯកសារបញ្ជាក់ថាបានរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមលក្ខខណ្ឌតម្រូវ ក្នុងចំណុច ក១ ឬ ក២

៦. ឯកសារបញ្ជាក់អំពីការបណ្តុះបណ្តាលជាប្រចាំដើម្បីរក្សាបាននូវសមត្ថភាពវិជ្ជាជីវៈនិងគុណភាពសេវាយ៉ាងតិចចំនួន៤០ម៉ោង ក្នុងមួយឆ្នាំ

៧. ប្រវត្តិរូបសង្ខេប (CV)

៨. សញ្ញាបត្រខ្ពស់បំផុត និងសញ្ញាបត្រគណនេយ្យករជំនាញ

៩. ឯកសារផ្សេងទៀត ដែលតម្រូវដោយអគ្គលេខាធិការនៃ **ក.ជ.គ.**

គ២. នីតិបុគ្គល

១. សារតាក្រុមហ៊ុន និងរចនាសម្ព័ន្ធក្រុមហ៊ុន

២. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

៣. លិខិត ឬវិញ្ញាបនបត្រសមាជិករបស់ **វ.គ.ស.ក.**

៤. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ

៥. បញ្ជីឈ្មោះនាយកសវនករ/ ដៃគូសវនករ/ សវនករប្រតិស្រុត និងមន្ត្រីជាន់ខ្ពស់ និងប្រវត្តិរូបសង្ខេប

៦. នីតិវិធីសវនកម្ម (សម្រាប់ក្រុមហ៊ុនសវនកម្ម)

៧. របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យជាធរមានសម្រាប់រយៈពេល២ឆ្នាំចុងក្រោយ (ករណីការស្នើសុំបន្ត)

៨. អាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈសវនកម្ម ដែលចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យ (ករណីការសុំបន្ត)

៩. ឯកសារផែនការយុទ្ធសាស្ត្រនិងផែនការបណ្តុះបណ្តាលបុគ្គលិកជាជនជាតិខ្មែរឱ្យក្លាយជាគណនេយ្យ-ករជំនាញ រយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ

១០. ឯកសារផ្សេងទៀត ដែលតម្រូវដោយអគ្គលេខាធិការនៃ **ក.ជ.គ.**។

**ឃ- សិទ្ធិ និងកាតព្វកិច្ចរបស់គណនេយ្យករ និងសវនករប្រតិស្រុត ជាជនបរទេស**

បន្ទាប់ពីទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាជាតិគណនេយ្យ, គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុតជាជនបរទេស មានសិទ្ធិ និងកាតព្វកិច្ច ដូចខាងក្រោម÷

**ឃ១. សិទ្ធិ**

- មានសិទ្ធិធ្វើជានាយកសវនករ/ ដៃគូសវនករ/ សវនករប្រតិស្រុត ដើម្បីសុំអាជ្ញាបណ្ណ/ការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របច្បាប់
- មានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍សវនកម្មឯករាជ្យ។

**ឃ២. កាតព្វកិច្ចរបស់គណនេយ្យករជំនាញ និងសវនករបរទេស ÷**

- គោរពបានយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករ និង ស្តង់ដាបច្ចេកទេសពាក់ព័ន្ធជាធរមាន ក្នុងព្រះរាជាណាចក្រកម្ពុជា
- ចុះហត្ថលេខាលើចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និងរបាយការណ៍សវនកម្មឯករាជ្យ ក្នុងនាមក្រុមហ៊ុន ដោយមានដាក់ឈ្មោះគណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត
- ដាក់ពាក្យស្នើសុំសិទ្ធិបន្តចុះហត្ថលេខា សម្រាប់រយៈពេល ១ឆ្នាំម្តង ហើយការស្នើសុំត្រូវធ្វើឡើងឱ្យបានរយៈពេលចំនួនពីរ (២)ខែ មុនការអនុញ្ញាតផុតសុពលភាព
- អនុវត្តតាមបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ ជាធរមាន
- ប្រើប្រាស់បុគ្គលិកជាជនជាតិខ្មែរ ដោយគោរពតាមលក្ខខណ្ឌតម្រូវនានាស្របតាមច្បាប់ស្តីពីការងារ
- បណ្តុះបណ្តាលបុគ្គលិកជាជនជាតិខ្មែរ ឱ្យក្លាយជាគណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត
- រកគណនេយ្យករជំនាញជាជនជាតិខ្មែរ ឬ/និង ដៃគូសវនករជាជនជាតិខ្មែរ ដើម្បីចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និងរបាយការណ៍សវនកម្ម ក្នុងរយៈពេលពីរ (០២)ឆ្នាំយ៉ាងយូរ គិតចាប់ពីថ្ងៃចេញសារាចរណែនាំនេះ

- មានធានារ៉ាប់រងការប្រកបវិជ្ជាជីវៈសមស្របសម្រាប់ក្រុមហ៊ុន
- រាយការណ៍ពីលទ្ធផលនៃការអនុវត្តផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់ខ្លួន មកអគ្គលេខាធិការដ្ឋាននៃ **ក.ជ.គ.** ជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យនិងវាយតម្លៃ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់
- ផ្ញើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ យ៉ាងយូរក្នុងសប្តាហ៍ទី៣ នៃត្រីមាស និងឆ្នាំបន្ទាប់ ដោយប្រើទម្រង់ដែលកំណត់ដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ
- សហការផ្តល់ព័ត៌មាននានាដែលតម្រូវដោយអគ្គលេខាធិការដ្ឋាន **ក.ជ.គ.**
- ជូនដំណឹងមកអគ្គលេខាធិការដ្ឋាន **ក.ជ.គ.** ក្នុងរយៈពេល១៥ ថ្ងៃ មានជាអាទិ៍÷
  - ការផ្លាស់ប្តូរនាយកសវនករ/ដៃគូសវនករ/ សវនករប្រតិស្រុត ឬគណនេយ្យករជំនាញក្នុងក្រុមហ៊ុន
  - ការសុំព្យួរអាជ្ញាបណ្ណ ឬការឈប់ប្រកបវិជ្ជាជីវៈដោយខ្លួនឯង
  - ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគហ៊ុននិក
  - ការផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម ឬមធ្យោបាយទាក់ទង។
- គោរព និងអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ខ- ទោសទណ្ឌ**

រាល់ការមិនគោរពតាមលក្ខខណ្ឌតម្រូវ និងកាតព្វកិច្ចនានា តាមខ្លឹមសារនៃសារាចរណែនាំនេះ គណនេយ្យករជំនាញ ឬ/និងសវនករប្រតិស្រុត ជាជនបរទេស និងនីតិបុគ្គលដែលមានគណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេសនឹងមិនត្រូវបានផ្តល់សិទ្ធិបន្តដើម្បីចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ ឬ/និងរបាយការណ៍សវនកម្មឯករាជ្យឡើយ ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។

គណនេយ្យករជំនាញ ឬ/និង សវនករប្រតិស្រុត ជាជនបរទេស និងនីតិបុគ្គលដែលមានគណនេយ្យករជំនាញ ឬ/និងសវនករប្រតិស្រុតជាជនបរទេស និងគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៥ រោច ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០២០

**រដ្ឋលេខាធិការ**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជា ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឌី_តាយី**

**កន្លែងទទួល÷**

- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី - រដ្ឋមន្ត្រី ស.ហ.វ
  "ដើម្បីគោរពជូនជ្រាប"
- គ្រប់សាលារាជធានី-ខេត្ត
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
  "ដើម្បីជូនជ្រាបនិងសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ